Office of the Minnesota Secretary of State (ការិយាល័យរដ្ឋលេខាធិការនៃរដ្ឋមីណេសូតា)

First National Bank Building,
332 Minnesota Street, Suite N201
Saint Paul, MN 55101
business.services@state.mn.us
651-296-2803

# សេវាអាជីវកម្ម

# លក្ខខណ្ឌតម្រូវថ្មីអំពីការរាយការណ៍ទៅសហព័ន្ធសម្រាប់ព័ត៌មានភាពជាម្ចាស់ទទួលផល (BOI)

ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2024 ក្រុមហ៊ុនជាច្រើននៅសហរដ្ឋអាមេរិកត្រូវតែរាយការណ៍ព័ត៌មានអំពី**ម្ចាស់ទទួលផល** ពោលគឺបុគ្គលដែលជាម្ចាស់ ឬគ្រប់គ្រងក្រុមហ៊ុនទៅ Financial Crimes Enforcement Network (FinCEN, បណ្តាញអនុវត្តន៍ច្បាប់ឧក្រិដ្ឋកម្មហិរញ្ញវត្ថុ) របស់ United States Department of the Treasury (ក្រសួងរតនាគារនៃសហរដ្ឋអាមេរិក)។ ការដាក់បញ្ជូនឯកសារនេះគឺ**ឥតគិតថ្លៃ** និងអាចបំពេញតាមអនឡាញតាមរយៈគេហទំព័រ www.fincen.gov/boi។

## តើខ្ញុំត្រូវរាយការណ៍ឬ?

**អាជីវកម្មភាគច្រើននៅរដ្ឋមីណេសូតាគឺជាអាជីវកម្មខ្នាតតូចដែលអាចនឹងត្រូវដាក់បញ្ជូនឯកសារ។**

ក្រុមហ៊ុនរបស់អ្នកអាចនឹងត្រូវរាយការណ៍ព័ត៌មានអំពីម្ចាស់ទទួលផល ប្រសិនបើក្រុមហ៊ុននោះជា៖

1. សាជីវកម្ម ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់ (LLC) ឬត្រូវបានបង្កើតនៅសហរដ្ឋអាមេរិកតាមរយៈការដាក់បញ្ជូនឯកសារទៅការិយាល័យរដ្ឋលេខាធិការ ឬការិយាល័យស្រដៀងគ្នានេះស្របតាមច្បាប់រដ្ឋ ឬកុលសម្ព័ន្ធជនជាតិដើម ឬ
2. ក្រុមហ៊ុនបរទេស និងបានចុះបញ្ជីធ្វើអាជីវកម្មនៅរដ្ឋ ឬកុលសម្ព័ន្ធជនជាតិដើមណាមួយនៃសហរដ្ឋអាមេរិកតាមរយៈការដាក់បញ្ជូនឯកសារនេះ។

**អង្គភាព 23 ប្រភេទត្រូវបានលើកលែង**ពីលក្ខខណ្ឌតម្រូវអំពីការរាយការណ៍ព័ត៌មានភាពជាម្ចាស់ទទួលផលនេះ។ សេចក្តីណែនាំស្តីពីអនុលោមភាពសម្រាប់អង្គភាពខ្នាតតូចរបស់ FinCEN រួមបញ្ចូលបញ្ជីត្រួតពិនិត្យសម្រាប់ការលើកលែងនីមួយៗទាំង 23 ដែលអាចជួយកំណត់ថាតើក្រុមហ៊ុនរបស់អ្នកត្រូវនឹងលក្ខខណ្ឌទទួលបានការលើកលែងឬអត់។ ចូលទៅកាន់ **www.fincen.gov/boi** ឬស្កេនកូដ QR ដើម្បីចូលមើលសេចក្តីណែនាំនេះ និងពិនិត្យមើលថាតើក្រុមហ៊ុនរបស់អ្នកត្រូវបានលើកលែងឬអត់។

*សេចក្តីណែនាំស្តីពីអនុលោមភាពសម្រាប់អង្គភាពខ្នាតតូច*

## តើខ្ញុំរាយការណ៍តាមវិធីណា និងនៅពេលណា?

ក្រុមហ៊ុនដែលរាយការណ៍នឹងត្រូវរាយការណ៍ព័ត៌មានភាពជាម្ចាស់ទទួលផលតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈគេហទំព័ររបស់ FinCEN៖ www.fincen.gov/boi។

FinCEN បានចាប់ផ្តើមទទួលយកការរាយការណ៍នៅថ្ងៃទី 1 ខែមករា ឆ្នាំ 2024។

- ប្រសិនបើក្រុមហ៊ុនរបស់អ្នកត្រូវបានបង្កើត ឬចុះបញ្ជីនៅមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2024 អ្នកនឹងមានពេលរហូតដល់ថ្ងៃទី 1 ខែមករា ឆ្នាំ 2025 ដើម្បីរាយការណ៍អំពី BOI។
- ប្រសិនបើក្រុមហ៊ុនរបស់អ្នកត្រូវបានបង្កើត ឬចុះបញ្ជីនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2024 ឬក្រោយពីនេះ អ្នកត្រូវតែរាយការណ៍អំពី BOI ក្នុងចន្លោះពេល 90 ថ្ងៃក្រោយពេលជូនដំណឹងអំពីការបង្កើត ឬការចុះបញ្ជី។ ចាប់ពីឆ្នាំ 2025 ចន្លោះពេលរាយកាណ៍នេះមានរយៈពេល 30 ថ្ងៃ។
- រាល់ការធ្វើបច្ចុប្បន្នភាព ឬការកែតម្រូវព័ត៌មានម្ចាស់ទទួលផលដែលអ្នកបានផ្តល់កាលពីមុនឱ្យ FinCEN ត្រូវតែដាក់បញ្ជូនក្នុងចន្លោះពេល 90 ថ្ងៃ។